សេចក្តីព្រាងដោយក្រុម SNEC
ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៥
ម៉ោង ១២៖០០នាទី

# សុន្ទរកថា
# សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីបើកសន្និសីទប្រចាំឆ្នាំចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២៥ ក្រោមប្រធានបទ
# «យុទ្ធសាស្ត្រកំណើនថ្មីរបស់ប្រទេសកម្ពុជា៖ អាទិភាពសម្រាប់ការអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់ និងនិរន្តរភាព»

រាជធានីភ្នំពេញ, ថ្ងៃ អង្គារ ៦ កើត ខែ ផល្គុន ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨
ត្រូវនឹងថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០២៥, សណ្ឋាគារសុខាភ្នំពេញ

- *ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល,*
- *ឯកឧត្តម, លោកជំទាវ, លោកអ្នកឧកញ៉ា, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី និង ភ្ញៀវកិត្តិយស ទាំងអស់ជាទីមេត្រី!*

ខ្ញុំ ពិតជាមានសេចក្តីរីករាយក្រៃលែង ដែលបានចូលរួមជាអធិបតី ជាលើកទី ២ ក្នុងពិធីបើកនៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី១៦ ឆ្នាំ ២០២៥ ក្រោមប្រធានបទ **«យុទ្ធសាស្ត្រកំណើនថ្មីរបស់ប្រទេសកម្ពុជា៖ អាទិភាពសម្រាប់ការអភិវឌ្ឍប្រកបដោយគុណភាពខ្ពស់ និង និរន្តរភាព»** ។ ខ្ញុំសូមថ្លែងអំណរគុណ និង វាយតម្លៃខ្ពស់ចំពោះ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដោយមានការសហការជាពិសេសពីកម្មវិធីភាពជាដៃគូប្រទេសកម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED), ដែលបានរៀបចំសន្និសីទដ៏មានសារសំខាន់នេះឡើង ។

ខ្ញុំក៏សូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន ថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល, អង្គទូត, ដៃគូអភិវឌ្ឍ, អង្គការជាតិ និងអន្តរជាតិ, វិស័យឯកជន និងវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយ និងគ្រឹះស្ថានសិក្សានានា ដែលបានអញ្ជើញចូលរួមដោយផ្ទាល់ក្នុងសន្និសីទនាពេលនេះ ។ ជាមួយគ្នានេះ, ខ្ញុំក៏សូមលើកទឹកចិត្តឱ្យមានការចូលរួមពីសំណាក់យុវជន និងនិស្សិត ដែលជាមូលធនមនុស្ស និងជាអនាគតអ្នកដឹកនាំបន្តវេនរបស់យើង ដើម្បីជាឱកាសក្រេបយកចំណេះដឹងពាក់ព័ន្ធនឹងការអភិវឌ្ឍទៅអនាគតរបស់កម្ពុជា ។

ឆ្លៀតឱកាសនេះ, ខ្ញុំសូមចូលរួមអបអរសាទរចំពោះ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាលធនាគារជាតិនៃកម្ពុជា ដែលត្រូវបានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI បានជ្រើសតាំងជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រោមការចង្អុលបង្ហាញរបស់ **លោកជំទាវបណ្ឌិត** វិទ្យាស្ថាន CDRI នឹងទទួលបានការ-រីកចម្រើនបន្ថែមទៀតទាំងផ្នែកសមត្ថភាពស្ថាប័ន និងទាំងផ្នែកគុណភាព និងគុណ-តម្លៃខ្ពស់នៃកិច្ចការស្រាវជ្រាវ សម្រាប់ជាធាតុចូលដល់ការរៀបចំ និងតាក់តែងគោល-នយោបាយរបស់រាជរដ្ឋាភិបាល និងជាឧត្តមប្រយោជន៍ដល់សាធារណជនទូទៅ ជាពិសេសអ្នកស្រាវជ្រាវ និងសិស្ស-និស្សិតរបស់យើង ផងដែរ ។

ខ្ញុំអាចនិយាយបានថា **សន្និសីទឆ្នាំ ២០២៥** នេះ គឺមានសារសំខាន់ និងរឹតតែ-វិសេស ជាងសន្និសីទរាល់ដង ក្នុងន័យថា សន្និសីទឆ្នាំនេះ បានប្រមូលផ្តុំធាតុចូលទាំងឡាយពីសន្និសីទមុនៗកន្លងទៅ និងបូកផ្សំនឹងការសិក្សាស្រាវជ្រាវបន្ថែមពីអ្នកស្រាវជ្រាវជំនាញរបស់វិទ្យាស្ថាន CDRI ពីនិន្នាការបច្ចុប្បន្ន ដើម្បីធ្វើការវែកញែកពិភាក្សា ក្នុងគោលបំណងកំណត់នូវទស្សនរួម អំពីទិសដៅអភិវឌ្ឍន៍កម្ពុជា ក្នុងដំណើរឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ ។ ក្នុងន័យនេះ, ខ្ញុំសូមលើកទឹកចិត្តឱ្យមានការពិភាក្សាដេញដោលយ៉ាងផុលផុស ពីសំណាក់វាគ្មិនជាតិ និងអន្តរជាតិ ក៏ដូចជាឯកឧត្តម, លោកជំទាវ, លោក លោកស្រី ដែលមានវត្តមានចូលរួមសន្និសីទនាថ្ងៃនេះ ។ មតិយោបល់ដែលបានមកពីការពិភាក្សាដេញដោលក្នុងថ្ងៃនេះ នឹងក្លាយជាធាតុចូលប្រកបដោយសារវន្ត និងគុណតម្លៃ ដែលសបញ្ជាក់ឱ្យឃើញពីការចូលរួមឈឺឆ្អាល, គិត-គូរតម្រែតម្រង់ទិស ក្នុងការកំណត់ជោគវាសនារួមរបស់ប្រទេសជាតិ ក្នុងស្មារតីភាពជាម្ចាស់ការ និងសាមគ្គីភាពជាតិ ។

– *ឯកឧត្តម, លោកជំទាវ, លោកអ្នកឧកញ៉ា, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

ជាការពិត, ដើម្បីគិតគូររៀបចំយុទ្ធសាស្ត្រកំណើនសម្រាប់អនាគត ជាពិសេសកំណើនក្នុងរយៈពេលវែងខាងមុខ, យើងចាំបាច់ពិនិត្យ និងត្រូវឈរលើមូលដ្ឋាននៃកំណើនក្នុងអតីតកាល, និន្នាការកំណើនក្នុងពេលបច្ចុប្បន្ន និងសក្តានុពលកំណើននាពេលអនាគត ។

ខ្ញុំសូមសង្ខេបឡើងវិញនូវនិន្នាការសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩ ដែលជាចំណុចរបត់ថ្មីនៃវដ្តកំណើនរបស់កម្ពុជាតែម្តង ។ ក្រោយពីបានយកឈ្នះលើសមរភូមិជំងឺកូវីដ-១៩, ដែលកាលនោះ កម្ពុជាមិនត្រឹមតែប្រយុទ្ធក្នុងសមរភូមិសុខភាពសាធារណៈប៉ុណ្ណោះទេ, ប៉ុន្តែក៏បានប្រយុទ្ធក្នុងសមរភូមិអប់រំ, គាំពារសង្គម, ហិរញ្ញវត្ថុ ក៏ដូចជាសេដ្ឋកិច្ច, ដែលកម្ពុជាបានបើកប្រទេសទាំងស្រុងវិញ នៅចុងឆ្នាំ ២០២១ និងបានអនុញ្ញាតឱ្យសកម្មភាពសង្គម-សេដ្ឋកិច្ច វិលទៅរកប្រក្រតីភាពឡើងវិញបន្តិចម្តងៗ ។ ជាក់ស្តែង, កំណើនសេដ្ឋកិច្ច បានវិលត្រលប់ទៅរកគន្លងសក្តានុពលវិញជាសន្សឹមៗ ក្នុងអត្រា ៣,១%, ៥,១%, ៥,០%, ៦,០% ក្នុងឆ្នាំ ២០២១, ២០២២, ២០២៣ និង ២០២៤ រៀងគ្នា ។ ក្នុងឆ្នាំ ២០២៥ នេះ, សេដ្ឋកិច្ចកម្ពុជារំពឹងថានឹងបន្តរក្សាបានចលនការរឹងមាំជាមួយនឹងអត្រាកំណើន **ក្នុងរង្វង់ ៦,៣%** ដែលបន្តទ្រទ្រង់ដោយវិស័យបម្រើការនាំចេញតួយ៉ាងដូចជាវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ, ការបន្តនិន្នាការកើនឡើងនៃវិស័យទេសចរណ៍ និងសេវាកម្មគាំទ្រ គួបផ្សំនឹងការបន្តរក្សាបានស្ថិរភាពកំណើននៃវិស័យកសិកម្ម ។

ក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ, រាជរដ្ឋាភិបាលនៅតែមានសុទិដ្ឋិនិយមខ្ពស់ថាកំណើនសេដ្ឋកិច្ចនៅមានលទ្ធភាពបន្តសម្រេចបាន **ក្នុងរង្វង់ ៦,៥% មធ្យមប្រចាំឆ្នាំ** ។ យ៉ាងណាមិញ, កំណើននេះនឹងមិនកើតឡើងដោយឯកឯងនោះទេ ប៉ុន្តែទាមទារការខិតខំប្រឹងប្រែងពីភាគីពាក់ព័ន្ធ, មិនត្រឹមតែពីសំណាក់រាជរដ្ឋាភិបាលនោះឡើយ, ក្នុងការពង្រឹងការអនុវត្តគោលនយោបាយ និងការដ្ឋានកែទម្រង់គន្លឹះៗ ។ ការវាយតម្លៃនេះក៏មានសង្គតិភាពទៅនឹងរបាយការណ៍សិក្សារបស់វិទ្យាស្ថាន CDRI ដែលនឹងត្រូវផ្សព្វផ្សាយក្នុងសន្និសីទនាថ្ងៃនេះ, ដោយបានលើកឡើងថា កម្ពុជាអាចសម្រេចបានក្នុងអត្រាកំណើន**ជាមធ្យមប្រចាំឆ្នាំ ប្រមាណ ៦,៤% ក្នុងទសវត្សរ៍ខាងមុខ** ក្នុងករណីមានការរៀបចំគោលនយោបាយជាក់លាក់, ចំៗ និង ជាក់ស្តែងនិយម អមជាមួយការអនុវត្តប្រកបដោយប្រសិទ្ធភាព ហើយទាំងនោះក៏ជាអ្វីដែលខ្ញុំសង្ឃឹមថានឹងទទួលបានចេញពីលទ្ធផលនៃសន្និសីទថ្ងៃនេះផងដែរ ។

ត្រង់ចំណុចនេះ, ខ្ញុំសូមទាញចំណាប់អារម្មណ៍នូវទិដ្ឋភាពសំខាន់ៗ ចំនួន ២ ដែលបង្កើតជាចំណុចរបត់ថ្មីនៃការគិតគូររៀបចំគោលនយោបាយ, ដែលនោះគឺ ៖ (១). បើទោះសេដ្ឋកិច្ចកម្ពុជាបានវិលត្រលប់ទៅរកកំណើនសក្តានុពលវិញក៏ពិតមែន **ប៉ុន្តែវិបត្តិជំងឺកូវីដ-១៩ បានបន្សល់ស្លាកស្នាម និងបន្ទប់បង្អាក់ដល់ល្បឿនអភិវឌ្ឍន៍របស់កម្ពុជា ជារួម,** និង (២). កម្ពុជា ក៏ដូចជាសេដ្ឋកិច្ចសកល និងតំបន់ គឺនៅបន្ត**ស្ថិតក្នុងអន្តរកាលនៃពហុវិបត្តិ**, ក្នុងន័យថា វិបត្តិមួយមិនទាន់ចប់រលត់ផង, វិបត្តិមួយទៀតក៏បានកើតឡើង, សង្គ្រាមមួយមិនទាន់បិទបញ្ចប់ផង, សង្គ្រាមមួយទៀតក៏បានកើតឡើង ។ ក្នុងនោះ, ហានិភ័យ និងភាពមិនប្រាកដប្រជា កើតមានកាន់តែច្រើនឡើងៗ រួមមាន ៖ (១). ការកើនឡើងនូវគោលនយោបាយគាំពារនិយម (Protectionism) និងសង្គ្រាមពាណិជ្ជកម្ម; (២). ភាពតានតឹងនៃកត្តាភូមិសាស្ត្រសេដ្ឋកិច្ចដែលអាចបន្ទប់បង្អាក់ដល់ច្រវាក់ផ្គត់ផ្គង់សកល និងនាំទៅដល់ការកើនថ្លៃទំនិញជាអន្តរជាតិ; (៣). ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម; និង (៤). ផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។ **អន្តរកាលនៃពហុវិបត្តិនេះ បានធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចសកល និងតំបន់មានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងមិនអាចរំពឹងទុកជាមុនបាន, ហើយនឹងបង្កជាកម្មវិបាក, ទាំងវិជ្ជមាន និងអវិជ្ជមាន, ទាំងផ្ទាល់ និងប្រយោល, ដល់សេដ្ឋកិច្ច និងសង្គមកម្ពុជា ផងដែរ ។**

- *ឯកឧត្តម, លោកជំទាវ, លោកអ្នកឧកញ៉ា, អ្នកឧកញ៉ា,ឧកញ៉ា, លោក, លោកស្រី!*

ជារួម, <u>និន្នាការទាំងនេះ, ជាកាលានុវត្តភាពផង និងជាហានិភ័យផង, តម្រូវឱ្យយើងគិតគូរឡើងវិញនូវយុទ្ធសាស្ត្រកំណើនក្នុងរយៈពេលវែង ដោយធានាសម្រេចឱ្យបាននូវគោលដៅកំណើនដែលគ្រោងទុកផង និងបន្តអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព, បរិយាប័ន្ន និងភាពធន់ ផងដែរ</u> ។ រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភាបានដាក់ចេញនូវ **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** ដើម្បី **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និងចីរភាព** ព្រមទាំងកំណត់យកនូវ **អាទិភាពគន្លឹះចំនួន ៥ ៖ មនុស្ស, ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យា** ដែលមានការគិតគូរជាលក្ខណៈយុទ្ធសាស្ត្រ ដោយឈរលើគោលការណ៍ ០២ សំខាន់ៗ គឺ ៖ **(ទី១).** បន្តថែរក្សាឱ្យបាននូវសន្តិភាព ដែលជាកត្តាសត្យានុម័ត ក្នុងការកសាងខឿនអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និង **(ទី២).** បន្តកសាង និងពង្រឹងមូលដ្ឋានគ្រឹះ សម្រាប់ពន្លឿនកិច្ចអភិវឌ្ឍប្រទេសជាតិក្នុងដំណើរឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០ ។

ផ្អែកលើយុទ្ធសាស្ត្រនេះ, ក្នុងរយៈពេលជាង ១៩ ខែកន្លងទៅនេះ, រាជរដ្ឋាភិបាលបានបន្តដាក់ចេញ និងអនុវត្តកម្មវិធី, យន្តការកែទម្រង់ និងវិធានការឆ្លើយតបជាបន្តបន្ទាប់ ។ ជាក់ស្តែង, ពាក់ព័ន្ធនឹង **«កម្មវិធីគោលនយោបាយអាទិភាព ៦»** និង **«វិធានការគន្លឹះទាំង ៥»**, រាជរដ្ឋាភិបាលបានដាក់ចេញយន្តការអនុវត្ត និងបន្តតាមដាន និងវាយតម្លៃ ដែលកន្លងទៅនេះ យើងអាចនិយាយបានថា ទទួលបាននូវលទ្ធផលគួរជាទីមោទនៈ ។ ទន្ទឹមនេះ, ក្នុងគោលដៅជំរុញពិពិធកម្មសេដ្ឋកិច្ច, បង្កើនភាពប្រកួតប្រជែង និងពង្រឹងភាពធន់, រាជរដ្ឋាភិបាលត្រៀមនឹងដាក់ឱ្យអនុវត្តនូវ **«កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ ឆ្នាំ ២០២៥ - ២០២៨»** ដោយផ្តោតលើសសរស្តម្ភ ៣ សំខាន់ៗ៖ **(ទី១). កម្មវិធីគាំទ្រសេដ្ឋកិច្ចតាមវិស័យក្នុងរយៈពេលខ្លីទៅមធ្យម** តាមរយៈការដាក់ចេញនូវវិធានការគោលនយោបាយមុតស្រួច និងចំគោលដៅ, **(ទី២). កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់** ដើម្បីដោះស្រាយបញ្ហាប្រឈម ដែលមានលក្ខណៈជារចនាសម្ព័ន្ធ, ស្មុគស្មាញ និងអន្តរវិស័យ និង **(ទី៣). កម្មវិធីត្រៀមលក្ខណៈចាកចេញពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួច** ដើម្បីធានានូវការចាកចេញដោយរលូន។

- *ឯកឧត្តម, លោកជំទាវ, លោកអ្នកឧកញ៉ា, អ្នកឧកញ៉ា,ឧកញ៉ា, លោក, លោកស្រី!*

ងាកមកសន្និសីទយើងក្នុងថ្ងៃនេះវិញ, ខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើលទ្ធផលនៃការសិក្សារបស់វិទ្យាស្ថាន CDRI និងប្រធានបទទាំង ៣ ដែលនឹងលើកយកមកពិភាក្សា ។ ការសិក្សាបានលើកឡើងពី «**យុទ្ធសាស្ត្រនៃកំណើនថ្មី**» ដែលការគួបផ្សំគ្នារវាងគោលនយោបាយកំណើនសេដ្ឋកិច្ចតាមវិស័យអាទិភាព ជាមួយនឹងការកែទម្រង់-រចនាសម្ព័ន្ធគ្រប់ជ្រុងជ្រោយ ។ ជារួម, យុទ្ធសាស្ត្រនេះផ្តល់សារសំខាន់លើ តុល្យភាពរវាងល្បឿននៃកំណើនសេដ្ឋកិច្ច ទៅនឹងគុណភាពនៃកំណើន ជាជាងការផ្តោតតែលើកំណើនខ្ពស់ ។ មានន័យថា, ទោះបីការកែទម្រង់រចនាសម្ព័ន្ធគ្រប់ជ្រុងជ្រោយ អាចបណ្តាលឱ្យកំណើនសេដ្ឋកិច្ចមានកម្រិតទាបជាងកំណើនសក្តានុពលក្តី ក៏ចាំបាច់ត្រូវទទួលយក ដើម្បីជំរុញលើកកម្ពស់គុណភាព, ចីរភាព និង បរិយាប័ន្ននៃកំណើន ដែរ ។ យុទ្ធសាស្ត្រនេះ ក៏មានភាពស៊ីចង្វាក់ទៅនឹង «**យុទ្ធសាស្ត្របញ្ចកោណ**» ជាច្រើន, ហើយដើម្បីសម្រេចបានកំណើនខ្ពស់ និង មានចីរភាព, ការកែទម្រង់រចនាសម្ព័ន្ធត្រូវតែធ្វើជាចាំបាច់ និងកាន់តែឆាប់, កាន់តែប្រសើរ ។ ទោះបីជាយ៉ាងនេះក្តី, ការកែទម្រង់មិនគួរត្រូវធ្វើដោយតក់ក្រហល់ពេល រហូតប៉ះពាល់ដល់សន្តិភាព និងស្ថិរភាពជារួមនោះទេ ។

ខ្ញុំក៏មានការចាប់អារម្មណ៍ចំពោះប្រធានបទនីមួយៗ ក្នុងកិច្ចពិភាក្សាទាំង ៣ វគ្គថ្ងៃនេះ ដែលមានជាអាទិ៍៖ សមិទ្ធកម្ម និង ទស្សនៈវិស័យកំណើន, ការកែទម្រង់រចនា-សម្ព័ន្ធ សម្រាប់កំណើនរយៈពេលវែង, និងការផ្សារភ្ជាប់គ្នាចក្ខុវិស័យកំណើនទៅនឹងអាទិភាពគោលនយោបាយ ។ ខ្ញុំសង្ឃឹមថា វគ្គពិភាក្សាដ៏មានសារសំខាន់ និងប្រទាក់-ក្រឡាគ្នានេះ នឹងអាចកំណត់ឱ្យកាន់តែច្បាស់នូវលំដាប់លំដោយអាទិភាព, តុល្យភាព, និងភាពអនុវត្តបាននូវបណ្តាគោលនយោបាយទាំងឡាយ ។

ដើម្បីបំផុសគំនិតសម្រាប់ការពិភាក្សាបន្ថែម, ខ្ញុំ សូមលើកនូវការអង្កេតមួយចំនួនពាក់ព័ន្ធនឹងបរិការណ៍ថ្មី ដោយតម្រង់ការពិភាក្សាលើទស្សនៈ និងកម្មវិបាកមកលើសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលខ្លី និង មធ្យម ។ **បរិការណ៍សកលសំខាន់ៗ ដែលគួរផ្ដោតការយកចិត្តទុក រួមមាន ៖** (១). ការកើនឡើងនូវចរន្តគាំពារនិយម ដែលអាចឈានទៅដល់សង្គ្រាមពាណិជ្ជកម្ម និងសង្គ្រាមបច្ចេកវិទ្យា; (២). ការចាប់ផ្តើមពឹងផ្អែកកាន់តែខ្លាំងឡើងលើសេដ្ឋកិច្ចក្នុងតំបន់ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច នៅពេលដែលប្រទេសក្នុងតំបន់កាន់តែរីកចម្រើនឡើង និងសមាហរណកម្មកាន់តែស៊ីជម្រៅ ខណៈដែលសេដ្ឋកិច្ចធំៗសម្រេចបានកំណើនទាប; (៣). សន្ទុះនៃការធ្វើបរិវត្តកម្មឌីជីថលកាន់តែលឿនជាពិសេសលើបញ្ញាសិប្បនិម្មិត, រ៉ូបូត និងស្វ័យប្រវត្តិកម្ម ដែលបើកលទ្ធភាពក្នុងការជំរុញផលិតភាពឱ្យមានសន្ទុះខ្ពស់ឡើង; និង (៤). និន្នាការកើនឡើងនៃអន្តរកាលបៃតងតួយ៉ាងដូចជាការវិនិយោគលើថាមពលកកើតឡើង និងរថយន្តអគ្គិសនី ជាដើម ។

ក្នុងបរិការណ៍កម្ពុជា, ខ្ញុំចង់ឱ្យមានការពិភាក្សាផុលផុសលើ ៖ (១). ការកំណត់និងអភិវឌ្ឍន៍វិស័យដែលជាប្រភពកំណើនថ្មី ជាពិសេសឧស្សាហកម្មយុទ្ធសាស្ត្រលេចឡើងថ្មីៗ និងការទាក់ទាញវិនិយោគដែលមានតម្លៃបន្ថែមខ្ពស់; (២). ការត្រៀមលក្ខណៈចាកចេញពីចំណាត់ក្រុមប្រទេសអភិវឌ្ឍតិចតួច (LDC); (៣). យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍសហគ្រាសធុនមីក្រូ, តូច និង មធ្យម និងធុរកិច្ចបង្កើតថ្មី តាមរយៈការបន្តពង្រឹងប្រព័ន្ធអេកូឡូស៊ី និងការបង្កើនសមត្ថភាព និងផលិតភាព; និង (៤). ការអភិវឌ្ឍជំនាញបច្ចេកទេស បំពេញគម្លាតនៃជំនាញ (Skill gap) និងការបំពេញតម្រូវការនាពេលអនាគត ។

ដូចនេះ, សន្និសីទរបស់យើងនាថ្ងៃនេះ គឺត្រូវតែជាវេទិកានៃការផ្លាស់ប្តូរយោបល់ត្រង់ទៅត្រង់មក, ប្រកបដោយស្មារតីស្ថាបនា និងចូលរួមគិតគូរ, អនុវត្ត និងទទួលខុសត្រូវរួមគ្នាលើជោគវាសនារបស់កម្ពុជា ។ ហើយធាតុចូលដែលបានមកពីការពិភាក្សាទាំង ៣ វគ្គនេះ នឹងផ្តល់ជាមូលដ្ឋានដ៏សំខាន់សម្រាប់រាជរដ្ឋាភិបាល ក្នុងការបំពេញបន្ថែមនូវចំណុចខ្វះចន្លោះ ផ្នែកគោលនយោបាយ និងវិធានការ ក្នុងន័យកែលម្អ, សម្រួច និងតម្រង់ទិសគោលនយោបាយឱ្យកាន់តែមានភាពប្រាកដនិយមខ្ពស់ និងចំគោលដៅ, ក៏ដូចជាការពង្រឹងការអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់ ។

- *ឯកឧត្តម, លោកជំទាវ, លោកអ្នកឧកញ៉ា, អ្នកឧកញ៉ា,ឧកញ៉ា, លោក, លោកស្រី!*

ឆ្លៀតឱកាសនេះ, ខ្ញុំក៏សូមកត់សម្គាល់ឡើងវិញអំពីតួនាទីដ៏សំខាន់នៃ «**ស្ថាប័នស្រាវជ្រាវ**» រួមទាំង វិទ្យាស្ថាន CDRI ក្នុងដំណើរការរៀបចំគោលនយោបាយ ក៏ដូចជាការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាទាំងមូល ។ ដូចនេះ, ខ្ញុំសូមផ្តល់ជាអនុសាសន៍ជូនវិទ្យាស្ថាន CDRI ដើម្បីបន្តពង្រឹងសមត្ថភាពស្ថាប័ន ជាពិសេសលើកិច្ចការស្រាវជ្រាវរបស់ខ្លួន ឱ្យកាន់តែមានគុណភាពខ្ពស់ប្រកបដោយគុណវុឌ្ឍិ សម្រាប់រាជរដ្ឋាភិបាល ក៏-ដូចជាសាធារណជនទូទៅ ដូចខាងក្រោម៖

**ទី១).ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នស្រាវជ្រាវក្នុងតំបន់** ដើម្បីទទួលបាននូវទស្សនាទានបន្ថែម ជាមួយនឹងចក្ខុវិស័យកាន់តែទូលំទូលាយ ក្នុងគោលដៅបង្កើនសមត្ថភាពរបស់ស្ថាប័ន សម្រាប់បម្រើដល់ការវិភាគ និងសិក្សាស្រាវជ្រាវ;

**ទី២).ការបំផុសគំនិតជជែកពិភាក្សាអំពីកិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា** ដើម្បីបន្តលើកកម្ពស់ការបំផុសស្មារតីចូលរួមជជែកពិភាក្សា, ផ្លាស់ប្តូរយោបល់ និងហ៊ានលើកជាមតិយោបល់ក្នុងន័យស្ថាបនា និងកែលម្អ; និង

**ទី៣).ការបន្តបំពេញតួនាទីជាសេវាមជ្ឈមណ្ឌលប្រមូលទិន្នន័យ និងបោះពុម្ពផ្សាយឯកសារស្រាវជ្រាវបែបបរិមាណវិស័យ និងគុណវិស័យ** ដើម្បីបន្តលើកកម្ពស់ការសិក្សាស្រាវជ្រាវដែលប្រើប្រាស់ព័ត៌មាន និងទិន្នន័យបឋម (Primary data) តាមរយៈការចុះប្រមូលទិន្នន័យ និង ស្ទង់មតិ ។ ត្រង់ចំណុចនេះ, ខ្ញុំសូមគូសបញ្ជាក់ថា សុក្រឹតភាព និងសង្គតិភាពនៃទិន្នន័យបឋម ឬ អាចហៅថាទិន្នន័យកម្រិតមីក្រូ (Micro data) គឺមានសារសំខាន់ណាស់សម្រាប់ជាធាតុចូលក្នុងការរៀបចំគោលនយោបាយ ឬ តម្រង់ទិសវិធានការគោល-នយោបាយឱ្យកាន់តែចំគោលដៅ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងស្របតាមស្មារតីរបស់រាជរដ្ឋាភិបាល **ដែលតែងតែចុះទៅស្តាប់ផ្ទាល់ និងប្រឡូកផ្ទាល់ជាមួយនឹងបញ្ហារបស់ប្រជាពលរដ្ឋ ហើយចូលរួមដោះស្រាយកង្វល់របស់ប្រជាពលរដ្ឋឱ្យចំគោលដៅ និងឱ្យចំឫសគល់នៃបញ្ហា ។**

- *ឯកឧត្តម, លោកជំទាវ, លោកអ្នកឧកញ៉ា, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

ខ្ញុំសង្ឃឹមជឿជាក់ថា សន្និសីទនាថ្ងៃនេះ នឹងប្រព្រឹត្តទៅដោយរលូន និងប្រកបដោយផ្លែផ្កា ។ ជាថ្មីម្តងទៀត, ខ្ញុំសូមលើកទឹកចិត្ត ឯកឧត្តម, លោកជំទាវ, លោកអ្នកឧកញ៉ា, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រីទាំងអស់ ចូលរួមឱ្យបានសកម្ម និងផុសផុល ក្នុងការពិភាក្សា ដើម្បីឱ្យសន្និសីទនាថ្ងៃនេះបញ្ចប់ទៅប្រកបដោយផ្លែផ្កា និងទទួលបានធាតុចូលសំខាន់ៗ សម្រាប់ជាជំនួយដល់ការវិភាគ និងការសន្និដ្ឋានរបស់វិទ្យាស្ថាន CDRI លើប្រធានបទដ៏មានសារសំខាន់ថ្ងៃនេះ ។

ជាចុងបញ្ចប់, ខ្ញុំសូមជូនពរ ឯកឧត្តម, លោកជំទាវ, លោកអ្នកឧកញ៉ា, អ្នកឧកញ៉ា, ឧកញ៉ា, លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ ឱ្យទទួលបានជោគជ័យ ក្នុងគ្រប់ភារកិច្ច និងជួបប្រទះនឹងពរ និងពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ, វណ្ណៈ, សុខៈ, ពលៈ និងបដិភាណ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើក **សន្និសីទប្រចាំឆ្នាំចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ ២០២៥** ចាប់ពីពេលនេះតទៅ ៕

*សូមអរគុណ!*